THE SCHOOL DISTRICT OF PHILADELPHIA

ការណែនាំសម្រាប់មាតាបិតា

# PSSA: ប្រព័ន្ធវាយតម្លៃសាលារបស់រដ្ឋផិនស៊ីលវេនញ៉ា

## តើការប្រឡង PSSA គឺជាអ្វី?

ប្រព័ន្ធវាយតម្លៃសាលានៅរដ្ឋផិនស៊ីលវេនញ៉ា (PSSA) គឺជាការវាយតម្លៃមូលដ្ឋានស្តង់ដារដែលផ្តល់ឲ្យសិស្ស មាតាបិតា អ្នកអប់រំ និងពលរដ្ឋឱ្យមានការយល់ដឹងអំពីលទ្ធផលរបស់សិស្ស និងសាលា ដែលទាក់ទងទៅនឹងការសំរេចបាននូវការស្ទាត់ជំនាញនៃការសិក្សាតាមស្តង់ដារ។ ស្តង់ដារទាំងនេះមាន អង់គ្លេស គណិតវិទ្យា និងវិទ្យាសាស្រ្ត ឲ្យដឹងថា សិស្សដឹង និងអាចធ្វើបានតាមកម្រិតថ្នាក់ខុសៗគ្នា។ សិស្សនៅរដ្ឋផិនស៊ីលវេនញ៉ា ដែលរៀនថ្នាក់ទី៣ ដល់ ទី៨ ត្រូវបានគេវាយតម្លៃលើមុខវិជ្ជាភាសាអង់គ្លេស និងគណិតវិទ្យា ហើយសិស្សនៅរដ្ឋផិនស៊ីលវេនញ៉ាដែលរៀនថ្នាក់ទី៤ និងទី៨ ត្រូវបានវាយតម្លៃផ្នែកវិទ្យាសាស្រ្ត។

## តើកូនខ្ញុំនឹងប្រឡង PSSA នៅពេលណា?

ការប្រឡង PSSA ត្រូវធ្វើឡើងប្រចាំឆ្នាំ ដែលមានរយៈពេលប្រឡង តាមធម្មតាបើកនៅ ខែមេសា និងឧសភា។ ប្រតិទិនសម្រាប់រយៈពេលនៃការប្រឡង PSSA អាចឃើញនៅ ត្រង់នេះ។ លោកអ្នកអាចមើល ប្រតិទិនសម្រាប់ការប្រឡងរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា ព្រមទាំងប្រតិទិនសាលារបស់កូនលោកអ្នក សម្រាប់កាលបរិច្ឆេទជាក់លាក់នៃពេលប្រឡង PSSAs នៅសាលារបស់ពួកគេ។

## តើគ្រូយកលទ្ធផលនៃការប្រឡង PSSA របស់កូនខ្ញុំទៅធ្វើអ្វី?

ពិន្ទុរបស់សិស្សម្នាក់ៗផ្តល់ទៅឲ្យតែសាលារបស់កូនលោកអ្នកតែប៉ុណ្ណោះ អាចប្រើដើម្បីជួយគ្រូក្នុងការធ្វើឲ្យដឹងពីភាពខ្លាំងពូកែ និងភាពអន់ខ្សោយរបស់កូនលោកអ្នក។ បន្ទាប់មកអនុញ្ញាតឱ្យគ្រូរៀបចំការបង្ហាត់បង្រៀន និងការហ្វឹកហាត់ដែលល្អសម្រាប់កូនលោកអ្នក ដើម្បីការគាំទ្រដ៏ល្អបំផុតដល់ការរីកចម្រើនក្នុងការសិក្សារបស់ពួកគេ។ ពិន្ទុប្រឡង PSSA ក៏ផ្តល់ព័ត៌មានដល់សាលា និងក្រសួងអប់រំ ដែលអាចគាំទ្រការកែលម្អ និងការរៀបចំផែនការពិភាក្សាពីកម្មវិធីសិក្សា និងការបង្ហាត់បង្រៀន ផងដែរ។

## តើសំណួរប្រភេទណាដែលសួរនៅក្នុងការប្រឡង PSSA?

សម្រាប់ការប្រឡង PSSA ភាសាអង់គ្លេស សំណួរជាច្រើនដែលសិស្សត្រូវឆ្លើយគឺសំណួរដែលមានចម្លើយសម្រាប់ជ្រើសរើស (multiple choice)។ ទោះជាដូច្នេះក៏ដោយ ក៏មានសមាសភាគនៃការសរសេរគ្រប់កម្រិតថ្នាក់ទាំងអស់។ សិស្សថ្នាក់ទី៣ត្រូវឆ្លើយបីសំណួរខ្លីៗតាមការបង្ហាញ ខណៈដែលសិស្សថ្នាក់ទី៤ ដល់ ទី៨ ត្រូវឆ្លើយតាមការវិភាគដែលពឹងផ្អែកលើអត្ថបទតាមការបង្ហាញ។ ចម្លើយខ្លីៗ និងចម្លើយតាមការវិភាគដែលពឹងផ្អែកលើអត្ថបទនឹងដាក់ពិន្ទុតាមការប្រើវិធី rubric។

សម្រាប់ការប្រឡង PSSAs គណិតវិទ្យា និងវិទ្យាសាស្រ្ត ដោយមិនគិតពីកម្រិតថ្នាក់ សិស្សទាំងអស់ត្រូវបានសួរសំណួរលាយគ្នា សំណួរដែលមានចម្លើយសម្រាប់ជ្រើសរើស និងសំណួរដែលសរសេរតាមគំនិតផ្ទាល់ខ្លួន។ ចម្លើយដែលសរសេរតាមគំនិតផ្ទាល់ខ្លួន ឲ្យពិន្ទុតាមការប្រើវិធី rubric។

ដើម្បីជ្រាបព័ត៌មានបន្ថែមអំពីប្រធានបទនេះ សូមមើលឯកសារដែលគេរៀបចំសម្រាប់ គណិតវិទ្យា អង់គ្លេស និង វិទ្យាសាស្រ្ត។

## តើពិន្ទុប្រភេទណាដែលរាយការណ៍នៅលើការប្រឡង PSSA?

សម្រាប់មុខវិជ្ជាដែលត្រូវប្រឡងទាំងបី សិស្សទទួលពិន្ទុដែលឆ្លើយត្រូវ (raw score) ពិន្ទុតាមស្តង់ដារ (scale score) និងពិន្ទុតាមកម្រិតដែលធ្វើបាន (ក្រោមកម្រិត ស្មើកម្រិត ស្ទាត់ជំនាញ ឬកំរិតខ្ពស់) ដែលជាប់ទាក់ទងនឹងពិន្ទុតាមស្តង់ដារជាក់លាក់។ ពិន្ទុតាមស្តង់ដារទាក់ទងនឹងកម្រិតដែលធ្វើបាននីមួយៗ ខុសគ្នាទៅតាមមុខវិជ្ជា។ សម្រាប់ការបែងចែកកាន់តែស៊ីជម្រៅ លោកអ្នកអាចមើល ឯកសារនៃកម្រិតពិន្ទុតាមស្តង់ដារ របស់ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេនញ៉ា។

លើសពីនេះទៀត ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេនញ៉ា ផ្តល់ឲ្យសាលានូវរបាយការណ៍នៃលទ្ធផលប្រឡងរបស់សិស្សម្នាក់ៗដោយរាយការណ៍ពីប្រភេទ និងគំរូនៃការវាយតម្លៃ (Assessment Anchor)។ គំរូនៃការវាយតម្លៃ តំណាងឲ្យប្រភេទនៃប្រធានបទ (ការស្ទាត់ជំនាញ និងដួងគំនិត) ដែលគាំទ្រខ្លឹមសារនៃការប្រឡង PSSA។ ការប្រឡងនីមួយៗមានពីរប្រធានបទ។

សម្រាប់ការប្រឡង PSSA អង់គ្លេស មានគំរូនៃការវាយតម្លៃបួន ដែលដូចគ្នាសម្រាប់ថ្នាក់ទី៣-ទី៨៖ គំនិត និងព័ត៌មានលម្អិត សិប្បកម្ម និងរចនាសម្ព័ន្ធ វាក្យសព្ទ និងភាសា។ ថ្នាក់ទី៤-៨ មានគំរូនៃការវាយតម្លៃបន្ថែមមួយទៀត៖ ការវិភាគដែលពឹងផ្អែកលើអត្ថបទ។

សម្រាប់ការប្រឡង PSSA គណិតវិទ្យា គំរូនៃការវាយតម្លៃ ខុសគ្នាតាមកម្រិតពិន្ទុ។ សម្រាប់ថ្នាក់ទី៣-ទី៥ គំរូនៃការវាយតម្លៃ គឺ៖ លេខ និងប្រមាណវិធីទាំងបួន ពីលេខ ០-៩ ប្រភាគ ប្រមាណវិធីទាំងបួន និងការគិតពិជគណិត ធរណីមាត្រ និងរង្វាស់ និងទិន្នន័យ (Numbers & Operations in Base Ten, Fractions, Operations & Algebraic Thinking, Geometry, and Measurement & Data)។ សម្រាប់ថ្នាក់ទី៦-ទី៧ គំរូនៃការវាយតម្លៃ គឺ៖ ប្រព័ន្ធលេខ អនុបាត និងទំនាក់ទំនងនៃសមាមាត្រ កន្សោម និងសមីការ ធរណីមាត្រ និងស្ថិតិ និងភាពអាចកើតឡើង (The Number System, Ratios & Proportional Relationships, Expressions & Equations, Geometry, and Statistics andProbability)។ សម្រាប់ថ្នាក់ទី៨ គំរូនៃការវាយតម្លៃ គឺ៖ ប្រព័ន្ធលេខ ផលចូល និងផលចេញ កន្សោម និងសមីការ ធរណីមាត្រ ស្ថិតិ និងភាពអាចកើតឡើង (The Number System, Functions, Expressions & Equations, Geometry, and Statistics and Probability)។

### តើមានន័យដូចម្តេចបើបានពិន្ទុ ក្រោមកម្រិត ស្មើកម្រិត ស្ទាត់ជំនាញ ឬកម្រិតខ្ពស់?

ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេនញ៉ា មាន ការពណ៌នាអំពីពិន្ទុតាមស្តង់ដារ សម្រាប់ គណិតវិទ្យា និង អង់គ្លេស នៅក្នុងវិបសៃរបស់គេ។

សម្រាប់ការប្រឡង PSSA វិទ្យាសាស្ត្រ គំរូនៃការវាយតម្លៃ គឺដូចគ្នាសម្រាប់ ថ្នាក់ទី៤ និងទី៨។ មានគំរូនៃការវាយតម្លៃមួយចំនួនដែលអាចដាក់ចូលគ្នាទៅក្នុងប្រភេទរបាយការណ៍ខាងក្រោមបានដោយមានរបៀបរៀបរយ៖ វិទ្យាសាស្ត្រធម្មជាតិ ជីវសាស្ត្រវិទ្យា វិទ្យាសាស្ត្ររូបនិយម និងធរណីវិទ្យា និងអវកាសវិទ្យា (Nature of Science, Biological Sciences, Physical Sciences, and Earth & Space Sciences)។

## តើការប្រឡង PSSA កំណត់ម៉ោងដែរឬទេ?

ការប្រឡង PSSA មិនកំណត់ម៉ោងទេ ប៉ុន្តែសិស្សមិនអាចបញ្ចប់ការប្រឡងផ្នែកមួយក្នុងរយៈពេលច្រើនថ្ងៃបានទេ។ ប្រសិនបើសិស្សចាប់ផ្តើមផ្នែកណាមួយនៅថ្ងៃច័ន្ទ ពួកគេមិនអាចបញ្ចប់ផ្នែកនោះនៅថ្ងៃអង្គារបានទេ។ សម្រាប់ភាសាអង់គ្លេស ការវាយតម្លៃត្រូវបែងចែកជាបីផ្នែក។ សម្រាប់គណិតវិទ្យា និងវិទ្យាសាស្ត្រ ការវាយតម្លៃត្រូវបែងចែកជាពីរផ្នែក។ ពេលវេលាប៉ាន់ស្មានដើម្បីបញ្ចប់ផ្នែកមួយនៃការប្រឡង PSSA ប្រែប្រួលទៅតាមប្រភេទសំណួរដែលបានសួរនៅក្នុងផ្នែកនីមួយៗ។ ដើម្បីជ្រាបព័ត៌មានបន្ថែមអំពីប្រធានបទនេះ រួមទាំងប្រភេទសំណួរដែលសួរក្នុងផ្នែកនីមួយៗ និងពេលវេលាប៉ាន់ស្មានដើម្បីបញ្ចប់ផ្នែកនីមួយៗ សូមមើលឯកសារដែលគេរៀបចំសម្រាប់ការប្រឡង គណិតវិទ្យា អង់គ្លេស និង វិទ្យាសាស្ត្រ។

## តើការប្រឡង PSSA ប៉ះពាល់ដល់ពិន្ទុរបស់កូនខ្ញុំដែរឬទេ?

ការប្រឡងនេះមិនប៉ះពាល់ដល់ពិន្ទុរបស់សិស្សទេ។

## តើកូនខ្ញុំប្រឡង PSSA ដោយរបៀបណា?

ការប្រឡង PSSA តាមធម្មតាធ្វើឡើងតាមការប្រើខ្មៅដៃ និងក្រដាស។ ទោះជាដូច្នេះក៏ដោយ ក៏មានវិធីប្រឡងតាមអ៊ិនធឺណែត ផងដែរ។ ដោយមិនគិតពីវិធីណាមួយដែលកូនរបស់លោកអ្នកប្រឡង សិស្សទាំងអស់ត្រូវតែទៅប្រឡង PSSA នៅសាលារបស់ពួកគេផ្ទាល់។

## តើខ្ញុំអាចមើលលទ្ធផលនៃការប្រឡង PSSA នៅទីណា?

សាលាទទួលរបាយការណ៍របស់សិស្សម្នាក់ៗពីរច្បាប់ រាល់រដូវស្លឹកឈើជ្រុះ។ លោកអ្នកអាចស្នើសុំរបាយការណ៍របស់សិស្សម្នាក់ៗមួយច្បាប់ពីសាលារបស់កូនលោកអ្នក។ លទ្ធផលក៏ចុះផ្សាយក្នុងគេហទំព័រសម្រាប់មាតាបិតា ក្រោមផ្នែកប្រឡងខ្នាតស្តង់ដារ (Standardized Test) នៃព័ត៌មានរបស់សិស្ស ផងដែរ។

## តើខ្ញុំអាចទាក់ទងទៅអ្នកណាបើខ្ញុំមានសំណួរថែមទៀតអំពីការប្រឡង PSSA?

ប្រសិនបើលោកអ្នកមានសំណួរថែមទៀតអំពីការប្រឡង PSSA យើងសូមឱ្យលោកអ្នកទាក់ទងទៅសាលារបស់កូនលោកអ្នក។ ព័ត៌សម្រាប់ទាក់ទងទៅសាលារបស់កូនលោកអ្នកអាចយកពី រ៉ិបសៃផ្ទុកព័ត៌មានសាលា ថ្មី របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា។

## តើខ្ញុំអាចរកព័ត៌មានបន្ថែមអំពីការប្រឡង PSSA នៅទីណា?

ការិយាល័យវាយតម្លៃសិស្សរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖ https://www.philasd.org/era/assessment/

គេហទំព័រស្តីអំពី PSSA របស់ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេនញ៉ា៖ https://www.education.pa.gov/K-12/Assessment%20and%20Accountability/PSSA/Pages/default.aspx